# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :...០...៧...អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការធ្វើអនុបយោគ និងការប្រគល់សិទ្ធិកាន់កាប់ដី ស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាង និង ភូមិស្ពានដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១ ._**

ត្រូវបានធ្វើអនុបយោគផ្ទៃដីទំហំ ២០១៧ហិកតា១៤ (ពីរពាន់ដប់ប្រាំពីរហិកតា និងដប់បួន) ស្ថិតនៅ ភូមិពូធឿង សង្កាត់បិតត្រាង និង ភូមិស្មាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ កាត់ចេញពីតំបន់គំរបព្រៃឈើឆ្នាំ២០០២ ដូចមានក្នុងផែនទីជាឧបសម្ព័ននៃអនុក្រឹត្យនេះ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ។

**មាត្រា ២ ._**

ត្រូវបានផ្ទេរនិងប្រគល់សិទ្ធិកាន់កាប់ផ្ទៃដីទំហំ ២០១៧ហិកតា១៤ (ពីរពាន់ដប់ប្រាំពីរហិកតា និងដប់បួន) ស្ថិតនៅភូមិពូធឿង សង្កាត់បិតត្រាង និងភូមិស្មាច់ដែង សង្កាត់រាម ខណ្ឌព្រៃនប់ ក្រុងព្រះសីហនុ ជូនក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខននើមី ហ្សូន ដើម្បីធ្វើការអភិវឌ្ឍន៍ជាតំបន់សេដ្ឋកិច្ចពិសេស ។

**មាត្រា ៣ ._**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៤ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខននើមី ហ្សូនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០០៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធ នៃអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី ២៧ ខែមករា

ផែនទី ទីតាំងតំបន់សេដ្ឋកិច្ចពិសេសសហគ្រាសស្ទឹងហាវ




**សញ្ញាសំគាល់**

- ចំណុចគោល
- ព្រំប្រទល់តំបន់សេដ្ឋកិច្ចពិសេស
- ក. វាលស្រែ ខ. វាលស្រែលិចទឹក
- ក. ចំការ ខ. ដំណាំក្នុងភូមិ
- ចំការដំណាំ
- ចំការឈើហូបផ្លែ
- កសិកម្មពនេចរ
- ដើមឈ្មោតដុះរាត់រាយ
- ក. ព្រៃស្រោងរបស់ឬព្រៃ ខ. ព្រៃស្តើង
- ក. ព្រៃគុម្ពោត ខ. វាលស្មៅ
- វាលស្មៅលិចទឹក
- ព្រៃគម្ពោតលិចទឹក
- ព្រៃលិចទឹក
- ក. ឆ្នេរខ្សាច់ ខ. ព្រៃកោងកាង

មាត្រដ្ឋាន ១ : ៤០ ០០០

**ប្រព័ន្ធកូអរដោនេ (COORDINATE SYSTEM)**

| | |
|---|---|
| បញ្ចាំងផែនទីលើប្លង់ (Projection) | : យូធីអឹម (UTM) |
| តំបន់ (Zone) | : ៤៨ |
| ទំនាក់ទំនងភូមិសាស្ត្រផ្ដេក (Horizontal datum) | : ដាប់ប៊្លិយូ ជី អេស ៨៤ (WGS 84) |
| ប្រព័ន្ធគ្រាប់ផែនដី (Spheroid) | : អេវឺរេស (Everest) |
| បណ្ដាញក្រឡាចត្រង្គ (UTM grid) | : ២ គីឡូម៉ែត្រ (2 Kilometers) |

**តារាង និយាមកាចំណុចកោងព្រំប្រទល់តំបន់សេដ្ឋកិច្ចពិសេស**

| ល.រ | អាប់ស៊ីស | អ័រដោនេ | ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|
| តំបន់ A | | | 32 | 354971.83 | 1173753.24 |
| 1 | 351624.34 | 1174444.58 | 33 | 354632.19 | 1173239.39 |
| 2 | 351554.02 | 1173434.07 | 34 | 354377.53 | 1173512.86 |
| 3 | 351236.46 | 1173004.32 | 35 | 354471.01 | 1173745.55 |
| 4 | 351229.74 | 1172572.96 | 36 | 354576.04 | 1173718.94 |
| 5 | 350283.71 | 1172498.71 | 37 | 354613.37 | 1173919.66 |
| 6 | 349644.34 | 1172676.68 | តំបន់ D | | |
| 7 | 349803.35 | 1172384.17 | 38 | 351316.95 | 1175663.23 |
| 8 | 349360.40 | 1172343.05 | 39 | 352621.00 | 1175618.00 |
| 9 | 349176.31 | 1172561.63 | 40 | 354048.32 | 1175509.77 |
| 10 | 349347.71 | 1172725.80 | 41 | 353614.00 | 1176504.00 |
| 11 | 349229.83 | 1172829.20 | 42 | 355038.00 | 1176561.00 |
| 12 | 349072.12 | 1172663.63 | 43 | 354855.66 | 1175146.54 |
| 13 | 348870.17 | 1172764.59 | 44 | 354857.00 | 1173787.00 |
| 14 | 349354.85 | 1173465.66 | តំបន់ E | | |
| 15 | 350058.45 | 1173535.68 | 45 | 349494.18 | 1179340.53 |
| 16 | 349993.56 | 1174439.72 | 46 | 350021.62 | 1180132.47 |
| 17 | 350457.14 | 1175840.64 | 47 | 349743.74 | 1180271.10 |
| 18 | 349871.00 | 1176096.00 | 48 | 349743.10 | 1180348.59 |
| 19 | 350078.00 | 1177090.00 | 49 | 349763.23 | 1180703.91 |
| 20 | 348839.80 | 1177286.74 | 50 | 349943.48 | 1180713.43 |
| 21 | 349348.90 | 1179436.16 | 51 | 349958.78 | 1180928.46 |
| តំបន់ B | | | 52 | 350046.63 | 1181010.10 |
| 22 | 352973.39 | 1173823.29 | 53 | 350840.64 | 1180473.78 |
| 23 | 352992.85 | 1173350.71 | 54 | 350622.12 | 1179418.69 |
| 24 | 352721.87 | 1173367.15 | 55 | 350384.30 | 1178443.59 |
| 25 | 352710.22 | 1173421.23 | តំបន់ F | | |
| 26 | 352467.65 | 1173500.96 | 56 | 348402.89 | 1176102.53 |
| 27 | 352468.90 | 1173668.48 | 57 | 347937.20 | 1176069.43 |
| 28 | 352090.71 | 1173605.11 | 58 | 347805.68 | 1176086.63 |
| 29 | 352081.73 | 1173759.96 | 59 | 347624.25 | 1176178.91 |
| 30 | 351830.00 | 1173909.00 | 60 | 347503.74 | 1176514.94 |
| 31 | 351812.69 | 1174363.06 | 61 | 347668.54 | 1176828.29 |
| តំបន់ C | | | 62 | 348045.96 | 1177022.15 |
| 32 | 354871.83 | 1173756.24 | 63 | 348202.27 | 1176718.70 |
| 33 | 354632.19 | 1173239.33 | 64 | 348483.24 | 1176878.19 |

| ល.រ | តំបន់ | ផ្ទៃដី (ហិកតា) |
|---|---|---|
| ១ | A | ១១១៣,៩៦ |
| ២ | B | ៥៦,៧៨ |
| ៣ | C | ១៦,២៧ |
| ៤ | D | ៥៦៥,៩៣ |
| ៥ | E | ១៩៥,២៧ |
| ៦ | F | ៦៧,៩៤ |
| ផ្ទៃដីសរុប | | ២០១៧,១៤ |